# ឯកសាររបស់អេកូអាស៊ី

## ការរៀនសូត្រពីកសិករ

*សរសេរដោយ រាចិន្រ្តា អូព្រីធី បោះពុម្ពជាថ្មីពីរឿងរ៉ាវកសិកម្ម មីនា ឆ្នាំ ២០១៣*

វាគឺជាពេលរសៀលមួយដែលខ្ញុំបានអានបរសនៅឆ្នាំ២០០២ជាលើកដំបូង។ ជាមន្ត្រីផ្សព្វផ្សាយក្នុងការិយាល័យអភិវឌ្ឍន៍កសិកម្មស្រុក ខ្ញុំចាប់ផ្តើមផ្សព្វផ្សាយពីបរសក្នុងឆ្នាំបន្ទាប់ក្នុងស្រុកម្វ៉ាំងប្រទេសនេប៉ាល់។ នៅពេលនោះ ខ្ញុំបានសង្កេតស្រែធ្វើស្រូវបរសនិងចំណាយពេលជាច្រើនឆ្នាំជាសកម្មជនបរស។ ដោយមើលទៅលើលទ្ធផល ខ្ញុំបានដឹងថាកសិករខុសៗគ្នាមានបញ្ហាខុសៗគ្នាហើយថា គេបានអនុវត្តបច្ចេកទេសទាំងអស់ដើម្បីអោយសមនឹងកាលទេសៈនិងតម្រូវការរបស់គេ។



*រដូវច្រូតកាត់ ចំណេះដឹងកសិករនិងសេចក្តីប្រាថ្នារបស់គេគឺជាចំណុចសំខាន់នៃការទទួលបានជោគជ័យ។ រូបភាពដោយ រាចិន្រ្តា អូព្រីធី*

ប្រព័ន្ធផ្សព្វផ្សាយនិងជាជើងឯកក្នុងតំបន់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកំពស់និងផ្សព្វផ្សាយបរសក្នុងប្រទេសនេប៉ាល់។ ក្នុងឆ្នាំ២០០៤ បរសត្រូវបាននែនាំក្នុងស្រុកម្វ៉ាំងជាមួយនឹង

គោលបំណងជាក់លាក់មួយគឺបង្កើនទិន្នផល។ ដាដូ DADO បានប្រើយុទ្ធសាស្ត្រវាលស្រែកសិករជាសាលារៀនដើម្បីបង្រៀនកសិករមួយចំនួនពីបច្ចេកទេសបរសនេះ អ្នកបណ្តុះបណ្តាលមានទាំងម្ចាស់ស្រែ អ្នកចូលគ្រាប់ពូជនិងកសិករដែលជួលដីស្រែ និងកសិករដែលមានធនធានទឹកគ្រប់គ្រាន់។

ក្នុងអំឡុងពេលនៃការប្រជុំក្នុងវាលស្រែជាអន្តរសកម្មភាព បរសហាក់ដូចជាស៊ីគ្នាជាមួយនឹងធាតុពិតនៃធនធានរបស់កសិករក្រីក្រដែលមានក្នុងតំបន់ ការខ្វះខាតដីនិងការប្រើប្រាស់របស់គេនៃគ្រាប់ពូជផ្សេងៗ។

តែតាមរយៈការធ្វើការជាមួយកសិករទាំងនេះមួយរយៈមក អ្នកស្រាវជ្រាវនិងបុគ្គលិកផ្សព្វផ្សាយបន្តរបានដឹងថា បរិបទផ្នែកកសិអេកូឡូស៊ីនិងសង្គមសេដ្ឋកិច្ចតែងតែខុសគ្នា ហើយថាយុទ្ធសាស្ត្របរសដែលរៀនបានថ្មីនេះត្រូវបានយកមកអនុវត្តន៍ខុសៗគ្នា ដោយយោងទៅតាមបរិបទ។

តម្រូវការស្រូវមានការកើនឡើងនៅប្រទេសនេប៉ាល់ដោយសារតែការកើនឡើងនៃប្រជាជននិងអំណាចនៃការទិញនៃផ្នែកខ្លះរបស់ប្រជាជន ហើយនិងការជួយដោយមធ្យោបាយដឹកជញ្ជូនមានភាពងាយស្រួលជាងមុន។ ស្រូវក្លាយទៅជាអទិភាពរបស់រដ្ឋាភិបាល ទៅជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរសង្គមនិងសេដ្ឋកិច្ចដែលៗបាននាំមកនូវឧកាសរកចំនូលថ្មីសំរាប់ប្រជាជនក្នុងតំបន់ដាច់ស្រយាល ហើយជាលទ្ធផលការធ្វើកសិកម្មស្រូវមានាករទាកទាញតិចតួច។

ទោះបីជាភាគច្រើននៃកសិករបានបន្តរការដាំស្រូវដើម្បីធនាពីតម្រូវការអាហាររបស់គេក៏ដោយ ក៏គេនៅតែមានការទាក់ទិននឹងសកម្មភាពបង្កើតប្រាក់ចំនូលបានពីកសិកម្មនិងមិនមែនកសិកម្មដែរ។ កសិករជំនាន់ថ្មីមានការចាប់អារម្មណ៍ច្រើនទៅលើបន្លែ ផ្លែឈើនិងដំណាំដែលមានតំលៃខ្ពស់។

ការសិក្សាលំអិតនៅទីវាលនៅស្រុកម៉្វាំងឆ្នាំ២០០៨ បានបង្ហាញថា បរសពិតជាបានបង្កើនការផលិតផលស្រូវ តែការទទួលយករបស់វានៅមានកំរិតនៅឡើយ។ ដោយការខ្វះកាទទួលបានទឹកចំងាយពីផ្ទះមកវាលស្រែ និងភាពជាម្ចាស់ និងការរកបាននូវកំឡាំងពលកម្មនិងការបណ្តុះបណ្តាលគឺជាកត្តាចំបងដែលកំណត់យុទ្ធសាស្ត្ររបស់កសិករ ដូច្នេះហើយតម្រូវអោយមានការផ្សព្វផ្សាយពីបរសនេះអោយបានច្រើន។

ដោយការទទួលបានទឹកដែលមិនអាចពឹងពាក់បាន ការធ្វើកសិកម្មក្នុងដីទំនាបច្រប់ ឬការធ្វើកសិកម្មស្រូវនៅលើដីជួលឬនៅឆ្ងាយពីផ្ទះ គឺជាឧបសគ្គក្នុងការអនុវត្តន៍បរស។ កសិករបរសភាគច្រើនបានប្រើគ្រួសារជាធនធានកំលាំងពលកម្ម ចំណែកឯកសិកខ្នាតធំ ពឹងផ្អែកទៅលើការជួលកំលាំងពលកម្ម មិនសូវចាប់អារម្មណ៍នឹងបរសទេព្រោះកំលាំងពលកម្មរបស់គេទាមទាពេលវេលា។

សរុបមក កត្តាដែលបានកំណត់គឺជាសារៈសំខាន់នៃការផលិតស្រូវក្នុងឧកាសបង្កើនប្រាក់ចំណូលដែលបានពីការធ្វើកសិកម្មនិងមិនមែនមកពីកសិកម្ម។ ការសិក្សានេះបានស្នើរថាបរសគឺមានការ

ទាក់ទាញទៅដល់កសិករដែលមានដីមួយចំណែកតូចដែលពឹងផ្អែកតិចតួចក្នុងការជួលកំលាំងពលកម្មគេ។

## ការបំរែបំរួលក្នុងការគ្រប់គ្រងវាលស្រែ

យើងនៅតែឃើញថាកសិករបានអនុវត្តន៍យុទ្ធសាស្រ្តគ្រប់គ្រងវាលស្រែផ្សេងៗពីគ្នាដើម្បីធ្វើការបញ្ចូលបរសទៅក្នុងប្រព័ន្ធកសិកម្មរបស់គេ។ កសិករតិចតួចប្រើប្រាស់ការអនុវត្តន៍បរសទាំង៦ដែលបាននែនាំក្នុងវគ្គបណ្តុះបណ្តាល (សំណាប់ខ្ចី សំណាប់តែមួយដើម មានគំលាតធំៗ រៀបចំប្រព័ន្ធស្រោចស្រពឆ្លាស់គ្នាទឹកផងគោកផង ការកំចាត់ស្មៅដែលជាយន្តការនិងការប្រើប្រាស់ជីកំប៉ុស្តិ) តែវិធីសាស្រ្តដែលត្រូវអនុវត្តន៍នេះទំនងជាមានជោគជ័យច្រើនជាងប្រព័ន្ធបរសស្តង់ដាទៅទៀត ដោយផលិតបានផលជាមធ្យម៥ចុច៧តោនក្នុងមួយហិតា។

ដោយការរក្សាអន្តសកម្មភាពយ៉ាងទៀងទាត់ជាមួយកសិករ អ្នកស្រាវជ្រាវនិងបុគ្គលិកផ្សព្វផ្សាយបន្តរបានដឹងថាអ្វីដំណើរការនិងអ្វីមិនដំណើរការ។ យើងរកឃើញថាកសិករដែលទទួលបានទិន្នផលច្រើនប្រើប្រាស់សំណាប់ខ្ចីជាងនិងសំណាបតិចជាងនៃពូជដែលបានចត គំលាតឆ្ងាយពីគ្នា។ ប្រភេទដីនិងការរកបាននៃទឹកបានជះឥទ្ធិពលយ៉ាងសំបើមថាយុទ្ធសាស្រ្តមួយណាដែលកសិករត្រូវជ្រើសរើស។

កសិករភាគច្រើនបានប្រើតែវិធីសាស្រ្តបរសក្នុងផ្នែកដែលខ្ពស់ជាងគេក្នុងវាលស្រែរបស់គាត់។ កសិករប្រើប្រាស់សំណាបខ្ចីជាងក្នុងកន្លែងដែលការស្រោចស្រពនិងបំពង់បង្ហូរមានភាពល្អប្រសើរ ដោយឆ្លើយតបទៅនឹងភស្តុតាងដែលការស្ទូងស្រូវនៅខ្ចីក្នុងកន្លែងអត់មានទឹកមានការប្រថុយប្រថានជាង។ ការមានទឹកក៏បានកំណត់ពីពេលនៃគារៀបចំដីនិងការស្ទូងដែរ។ នៅពេលដែលភ្លៀងមកយឺតឬនៅពេលដែលទឹកមិនអាចមាន ការរៀបចំវាលស្រែត្រូវបានពន្យាពេលខណះពេលដែលកូនសំណាបនៅបន្តរលូតលាស់ក្នុងថ្នាលសំណាប។

ទីពីរ ការកំចាត់ស្មៅដោយម៉ាស៊ីនអាចជាបញ្ហាដែរ ទោះបីជាកសិករប្រើប្រាស់កូនសំណាប់តិចក៏ដោយនិងគំលាតធំក៏ដោយ គេនៅមិនទាន់បានស្ទូងអោយត្រង់ជួរឬជាបួនជ្រុងចាំបាច់សំរាប់ការងាយស្រួលដល់ការកំចាត់ស្មៅដែរ។ ការគ្រប់គ្រងស្មៅ ដោយដៃឬដោយម៉ាស៊ីន ទាមទារអោយមានកំលាំងពលកម្មដែលមានគ្រប់គ្រាន់និងមានជំនាញ។ ការកំចាត់ស្មៅដោយម៉ាស៊ីនត្រូវបានរកឃើញថាបង្កើនទិន្នផលច្រើនជាង តែកសិករភាគច្រើនត្អូញពីឧបករណ៍កំចាត់ស្មៅផលិតក្នុងស្រុកដែលមានសូវបានប្រសិទ្ធិភាព។ សំភារៈដែលធ្ងន់ៗគឺមានសមស្របសំរាប់អ្នកធ្វើការជាស្រ្តីដែលធ្វើការច្រើនលើសលប់នោះឡើយ។

ទីបី កសិករជាច្រើនមិនធ្វើតាមដំបូន្មានក្នុងការប្រើប្រាស់ជីកំប៉ុស្តិ(តែឯងឬជាមួយជី) ជួនកាលអត់មានជីកំប៉ុស្តិដែលអាចរកបានឡើយ(មិនគ្រប់គ្រាន់) ជាពិសេសនៅពេលដែលអាចមិសត្វត្រូវបានប្រើប្រាស់ជាភ្លើង។ កត្តាដទៃទៀតដែលរាំងដល់ការប្រើប្រាស់ជីកំប៉ុស្តិមានទាំងចំងាយទៅស្រែ

ភាពជាម្ចាស់ដី និងការរំពឹងទុកពីផលដែលបានមកវិញ។ការប្រើរទេះគោក្នុងតំបន់មានការថយចុះ ជំរើសរបស់កសិករចំពោះការដឹកជញ្ជូននៅមានចំនួនមានកំរិត។

បន្ថែមពីនេះទៀត កសិករចូលចិត្តអនុវត្តន៍ជីកំប៉ុស្តិដែលអាចរកបាននៅលើដំណាំដែលមានតំលៃថ្លៃដូចជាបន្លែនិងគ្រឿងទេសជាង។ ការរកឃើញមួយទៀតគឺថាកសិករដែលផលិតបានតិចក្នុងតំបន់ដែលបានសិក្សាបានប្រើជីច្រើនជាងតម្រូវការ។ ផ្ទុយទៅវិញ កសិករដែលបានចូលរៀនវគ្គបណ្តុះបណ្តាលបានបន្ថយការប្រើប្រាស់ជីរបស់គេ។

ជាចុងបញ្ចប់ យើងឃើញថាកសិករមិនបានធ្វើតាមអ្វីដែលជាអនុសាសន៍នៃប្រព័ន្ធស្រាវជ្រាវជាលក្ខណះជាតិនោះឡើយ។មានតែ២២%ប៉ុណ្ណោះនៃវាលស្រែនៅស្រុកមូរ៉ាំងដែលបានដាំដុះជាមួយពូជស្រូវដែលបាននែនាំ។ ក្នុងតំបន់ដែលមានប្រពន្ធស្រោចស្រពល្អ(ដូច្នេះហើយមានការប្រឈមនឹងងាយរងគ្រោះតិចតួចជាង) ពូជដែលបាននែនាំបានលូតលាស់ល្អជាងហើយត្រូវបានយកមកអនុវត្តន៍ដោយកសិករ។តែមានប្រជាប្រិយភាពតិចតួចជាងក្នុងវាលស្រែដែលទទួលរងភាពងាយរងគ្រោះជាង។

ជាការបន្ថែម ទិន្នផលដែលមានជញ្ជ្រាំងទាបជាងនៃពូជស្រូវតឿធ្វើអោយមានការទាក់ទាញតិចជាងសំរាប់កសកិរដែលមានសត្វចិញ្ចឹម។ ពួកគេចូលចិត្តពូជខ្ពស់ជាជាងដែលអាចផ្តល់ជញ្ជ្រាំងដែលគេអាចប្រើប្រាស់ជាចំណី។ ផងដែរនោះ ខណះពេលដែលពូជបាសម៉ាតីដែលបានទិន្នផលតិចហើយចំណាយពេលយូរបែជាត្រូវបានដាំដុះដោយកសិករមួយចំនួនដោយសារតែតំលៃថ្លៃដែលគេអាចប្រមូលបាន។ ពួកវាមិនមានប្រជាប្រិយក្នុងចំណោមកសិករខ្នាតតូចនិងក្រីក្រឡើយ ដែលដាំស្រូវសំរាប់ការប្រើប្រាស់ជាលក្ខណះគ្រួសារ។ ពូជដែលមានប្រជាប្រិយមិនត្រូវបាននែនាំដោយប្រព័ន្ធស្រាវជ្រាវឡើយ តែត្រូវបានជ្រើសរើសនិងចែកចាយក្នុងបណ្តាញកសិករមួយទៅមួយទៀត។

## ការរៀនសូត្រពីកសិករ

ការនែនាំអោយស្គាល់បរសេក្នុងពេលវគ្គបណ្តុះបណ្តាលជាដូ បានជួយទាំងកសិករនិងបុគ្គលិកផ្សព្វផ្សាយបន្តរអោយបានរៀនពីវាលស្រែនិងពីគ្នាទៅវិញទៅមក។

បុគ្គលិកផ្សព្វផ្សាយបន្តរបានឃើញថាអនុសាសន៍ផ្ទាល់ខ្លួនរបស់គេមិនត្រូវបានយកមកអនុវត្តន៍ឡើយ ហើយបានចាប់ផ្តើមដំណើរការរំលឹកឡើងវិញនូវបច្ចេកទេសជាមួយកសិករ។ ការនេះបានធ្វើអោយបាក់បែកប្រព័ន្ធនៃការរៀនសូត្រអ្នកទទួលផលដែលមានការចែករំលែកក្នុងវិធីតែមួយជាជាលក្ខណះប្រពៃណីយ៍។

បន្ទាប់ពីចូលរួមសាកល្បងនិងការសិក្សាមក ទំនាក់ទំនងទៅវិញទៅមកបានក្លាយទៅជាពេញនិយម ទំនាក់ទំនងរបៀបនេះបានជួយកែច្នៃទ្រង់ទ្រាយនៃអនុសាសន៍ជាទូទៅរបស់បុគ្គលិក

ផ្សព្វផ្សាយបន្តរ។ នៅពេលដែលដាដូបានចាប់ផ្តើមបង្កើតជាអនុសាសន៍ផ្អែកលើការស្នើរសុំរបស់កសិករ កសិករដទៃទៀតបានចាប់អារម្មណ៍ក្នុងការសាកល្បងនិងចែករំលែកយុទ្ធាសស្រ្តថ្មីនេះ។




*ការធ្វើការរួមគ្នាជាមួយកសិករ យើងទាំងអស់គ្នាបានឃើញអ្វីដែលដំណើរការនិងមិនដំណើរការ រូបថត រាចិន្រ្តា អូព្រីធី*

បរសត្រូវបានឃើញថាមានប្រសិទ្ធិភាព តែមិនចាំបាច់អោយមានការចាប់អារម្មណ៍ដោយកសិករទាំងអស់និងគ្រាប់បរិបទនោះឡើយ។កសិករព្យាយាមកែទំរង់វាដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច

សង្គមនិងកសិអេកូឡូស៊ី ការជ្រើសរើសការអនុវត្តន៍ខ្លះដែលសមរម្យបំផុតសំរាប់ពួកគេនិងវាលស្រែជាពិសេសរបស់គេ។

ការនេះបានបង្រៀនយើង ដែលជាភ្នាក់ងារបន្តរ អោយគិតជាថ្មីទៀតពីដំណើរការផ្សព្វផ្សាយរបច្ចេកវិទ្យារបស់យើងសំរាប់កសិករខ្នាតមធ្យមនិងតូច ហើយចាប់ផ្តើមផ្តល់ដល់ពួកគេនូវជំរើសមួយចំនួន។ ជំរើសនេះគឺទំនងជាផ្សេងៗគ្នានិងបត់បែនល្មមអាចអោយកសិករជ្រើសរើសពីពួកគេដោយអាស្រ័យលើស្ថានភាពពិសេសរបស់គេ។

បើសិនជារដ្ឋាភិបាលនិងសេវាកម្មគាំទ្រដទៃទៀតចង់បង្កើនប្រយោជន៍ដែលកសិករអាចទទួលបានពីបច្ចេកទេសបរស ពួកគេត្រូវការដោះស្រាយបញ្ហាដែលជះឥទ្ធិពលដល់ការសំរេចចិត្តរបស់កសិករ ការធ្វើអោយប្រសើឡើងនូវប្រព័ន្ធចែកចាយទឹកនិងការទុកចិត្តបានរបស់គេអាចជាប្រយោជន៍សំរាប់កសិករដែលមានដីនៅទំនាប ដីច្រប់និងតំបន់ដែលមានធារាសាស្រ្តខ្សោយ។

ជំរើសមួយទៀតគឺជួយអោយកសិករទទួលបានការកំចាត់ស្មៅដោយម៉ាស៊ីនសមរម្យ។ យុទ្ធសាស្រ្តគ្រប់គ្រងអាហាររូបត្ថម្ភក៏អាចត្រូវបានលើកកំពស់ដោយការសំឡឹងមើលការផ្គត់ផ្គងជីហើយនិងផ្តល់ជូននូវវគ្គបណ្តុះបណ្តាលដ៏សំខាន់នៃការប្រើប្រាស់ជីអាចមិសត្វ។ យើងនៅតែព្យាយាមរក្សាក្នុងគំនិតរបស់យើងថាតម្រូវការកញ្ចប់វគ្គបណ្តុះបណ្តាលត្រូវតែរៀបចំឡើងដោយយោងទៅលើតម្រូវការក្នុងតំបន់។ហើយការផលិតស្រូវត្រូវការអោយក្លាយទៅជាជំរើសដ៏ទាក់ទាញបែបពាណិជ្ជកម្មចំពោះធនធានដទៃទៀតនៃចំណូល។

ចំណេះដឹងរបស់កសិករនិងសេចក្តីប្រាថ្នាផ្នែកជីវភាពរស់នៅគឺជាធាតុកំណត់ដ៏សំខាន់បំផុតនៃភាពជោគជ័យក្នុងវាលស្រែ។ ការសិក្សានេះបានរកឃើញថាអ្នកដែលជ្រើសរើសពូជបានល្អបំផុត ការជ្រើសរើសតាមបែបចូលរួមនិងយុទ្ធសាស្រ្តផ្សព្វផ្សាយគឺច្បាស់ណាស់ថាជាយុទ្ធសាស្រ្តដ៏ល្អបំផុតដើម្បីនៃនាំពូជស្រូវដែលមានជោគជ័យបំផុត។ ភាពចំរុះនៃពូជស្រូវនិងវិធីនៃការដាំដុះគឺជាធាតុដ៏សំខាន់នៃកសិកម្មស្រូវ ជាពិសេសក្នុងប្រទេសដូចជានេប៉ាល់នេះ ដែលភាគច្រើននៃកសិកម្មស្រូវគឺនៅតែប្រើប្រាស់បែបចាំភ្លៀង វាមានសារៈសំខាន់ណាស់ក្នុងការយល់ពីប្រព័ន្ធកសិកម្មស្រូវតាមបែបកសិអេកូឡូស៊ីនិងសង្គមសេដ្ឋកិច្ចចំរុះ។

*អំពីអ្នកនិពន្ធ រាចិន្រ្តា អូព្រីធី បានធ្វើការជាមន្រ្តីកសិកម្មជាន់ខ្ពស់ក្នុងមន្ទីរកសិកម្មប្រទេសនេប៉ាល់និងពេលនេះជាបេក្ខជនភីអេចឌី នៅសកលវិទ្យាល័យវាចេននីគេន*

*អរគុណជាពិសេសដល់សាស្រ្តាចារ្យ ថម គូភឺ និងវេជ្ជ ហារ៉ូ ម៉ាតនៅសកលវិទ្យាល័យវាចិនីគេន សំរាប់អនុសាសន៍ដ៏សំខាន់របស់លោក ការស្នើរជាយោបល់និងការគាំទ្រ។*